ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខៈ ៣១១៦ អយក.ស.ស.ព

នាយកដ្ឋានព័ត៌មាននិងកិច្ចការអាស៊ាន
ចូល លេខ 82
ថ្ងៃទី 17 ខែ 7 ឆ្នាំ 2015
ម៉ោង

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៥

ជម្រាបមក

- ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានអង្គភាពក្រោមឱវាទទីស្តីការក្រសួង
- លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត

**កម្មវត្ថុ ៖** ការប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តម "បរិញ្ញា+១" ជំនាន់ទី២១

**យោង ៖** លិខិតលេខ២៦៧២ អយក.បល ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តម លោកជំទាវ លោក លោកស្រីថា ៖ ក្នុងឆ្នាំ២០១៥នេះ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវការប្រឡងជ្រើសរើស និងបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តមចំនួន ១.០០០នាក់ តាមប្រព័ន្ធបណ្តុះបណ្តាល "បរិញ្ញា+១" ឱ្យចូលរៀន នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៥ នៅ វិទ្យាស្ថានជាតិអប់រំ ។

## I.លក្ខខណ្ឌនៃការជ្រើសរើស

ជ្រើសរើសក្នុងចំណោមបេក្ខជនទាំងពីរភេទ៖

១-ជានិស្សិតសុទ្ធសាធ ដែលពុំទាន់មានការងារក្នុងក្របខណ្ឌមន្ត្រីរាជការ ។

២-ជាបុគ្គលិកក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា ដែលបានតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីរាជការរួចហើយ។

៣-មានសញ្ជាតិខ្មែរ មានជីវប្រវត្តិច្បាស់លាស់ មានសុខភាពល្អ មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រ ឬសញ្ញាបត្រដែលមានតម្លៃសមមូលឡើងទៅ និងមានអាយុមិនលើសពី ៣០ឆ្នាំ សម្រាប់និស្សិតសុទ្ធសាធ និងអាយុក្រោម ៥៩ឆ្នាំ សម្រាប់បុគ្គលិកអប់រំ គិតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ២០១៥។

## II.ការប្រឡងជ្រើសរើស

១-កាលបរិច្ឆេទនៃការទទួលពាក្យសុំចុះឈ្មោះប្រឡង ចាប់ពីថ្ងៃប្រកាសផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោង៥:០០រសៀល ។

២-សម័យប្រឡង ៖ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥

៣-វិញ្ញាសាប្រឡង ៖ បេក្ខជនម្នាក់ៗត្រូវប្រឡង ២ វិញ្ញាសា រួមមាន ៖

-វិញ្ញាសា វប្បធម៌ទូទៅ រយៈពេល១ម៉ោង៣០នាទី មេគុណ១ (វិញ្ញាសារួមសម្រាប់គ្រប់មុខវិជ្ជាឯកទេស)

-វិញ្ញាសា ឯកទេស រយៈពេល៣ម៉ោង មេគុណ២

៤- ទីកន្លែងដាក់ពាក្យ ៖ វិទ្យាស្ថានជាតិអប់រំ

៥- សំណុំលិខិតរបស់បេក្ខជន៖ បេក្ខជនត្រូវបំពេញសំណុំលិខិតសុំចុះឈ្មោះប្រឡងដោយដៃផ្ទាល់រួមមាន៖

១- ពាក្យសុំចុះឈ្មោះប្រឡង (គំរូភ្ជាប់)........ ចំនួន០១ច្បាប់
២- សញ្ញាបត្របរិញ្ញាបត្រឬវិញ្ញាបនបត្របណ្ដោះអាសន្នថតចម្លង បញ្ជាក់ទទួលស្គាល់ដោយអាជ្ញាធរដែនដី ចំនួន០១ច្បាប់
៣- ប្រវត្តិរូបសង្ខេបមានបិទរូបថតថ្មីទំហំ៤ x ៦ (គំរូភ្ជាប់)........ ចំនួន០១ច្បាប់
៤- សលាកបត្រឯកត្តជនមានបិទរូបថតថ្មីទំហំ៤ x ៦ (គំរូភ្ជាប់)........ ចំនួន០២ច្បាប់
៥- វិញ្ញាបនបត្របញ្ជាក់សុខភាព និងកាយសម្បទា (បំពេញក្រោយប្រកាសលទ្ធផល)........ ចំនួន០១ច្បាប់
៦- លិខិតធានារបស់ឪពុកម្ដាយ ឬអាណាព្យាបាលសម្រាប់បេក្ខជនជានិស្សិតសុទ្ធសាធ (គំរូភ្ជាប់)........ ចំនួន០១ច្បាប់
៧- កិច្ចសន្យាស្ម័គ្រចិត្តបម្រើវិស័យអប់រំ យុវជន និងកីឡា (យ៉ាងតិច១០ឆ្នាំ) សម្រាប់បេក្ខជនជានិស្សិតសុទ្ធសាធ (គំរូភ្ជាប់)........ ចំនួន០១ច្បាប់
៨- ប្រកាសស្ដីពីការតាំងស៊ប់ក្នុងក្របខណ្ឌសម្រាប់បេក្ខជនជាបុគ្គលិកសិក្សា........ ចំនួន០១ច្បាប់
៩- វិញ្ញាបនបត្ររដ្ឋបាលសម្រាប់បេក្ខជនជាបុគ្គលិកសិក្សាបញ្ជាក់ដោយក្រសួង/មន្ទីរ (គំរូភ្ជាប់)........ ចំនួន០១ច្បាប់
១០-រូបថតថ្មីថតចំពីមុខ គ្មានពាក់មួក គ្មានពាក់វ៉ែនតា ទំហំ៤ x ៦........ ចំនួន០២សន្លឹក
១១-បង្កាន់ដៃបង់ប្រាក់សុំសិទ្ធិប្រឡង (២០០០៛)........ ចំនួន០១ច្បាប់

## III.ចំណែកចែកគរុនិស្សិតតាមរាជធានី-ខេត្ត ៖

តារាងជ្រើសរើសគរុនិស្សិតកម្រិតឧត្ដម "បរិញ្ញា+១" ជំនាន់ទី២១ (ជូនភ្ជាប់)

## ♦កំណត់សម្គាល់៖

១- បេក្ខជនដែលមានបរិញ្ញាបត្រផ្នែកនីតិសាស្រ្ត (នីតិរដ្ឋបាលសាធារណៈ នីតិឯកជន នីតិអន្តរជាតិ ទំនាក់ទំនងអន្តរជាតិ និងរដ្ឋបាលសាធារណៈ) សង្គមវិទ្យា ទស្សនវិជ្ជាពុទ្ធសាសនា ត្រូវជ្រើសរើសឯកទេសជាសីលធម៌ពលរដ្ឋវិជ្ជា។ បេក្ខជនដែលមានសញ្ញាបត្រផ្នែកវិទ្យាសាស្ត្រអប់រំ និងគ្រប់គ្រងអប់រំ ត្រូវជ្រើសរើសឯកទេសជាចិត្តវិទ្យា។ បេក្ខជនដែលមានសញ្ញាបត្រផ្នែកភូមិវិទ្យា និង បរិស្ថានអាចជ្រើសរើសឯកទេសជាផែនដីវិទ្យា។ បេក្ខជនដែលមានសញ្ញាបត្រផ្នែកបាលី-សំស្រ្កឹត និងភាសាវិទ្យា ត្រូវជ្រើសរើសឯកទេសជាអក្សរសាស្ត្រខ្មែរ ។ បេក្ខជនដែលមានសញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ វិទ្យាសាស្ត្រជលផល ក្សេត្រសាស្ត្រ ព្រៃឈើ ត្រូវជ្រើសរើសឯកទេសជាកសិកម្ម។ បេក្ខជនដែលមានសញ្ញាបត្រផ្នែកគ្រប់គ្រងពាណិជ្ជកម្ម (គ្រប់គ្រងគណនេយ្យ ហិរញ្ញវត្ថុ ធានាគារ ម៉ាឃីតទីង គ្រប់គ្រងសណ្ឋាគារ -បដិសណ្ឋារកិច្ច និងទេសចរណ៍) សេដ្ឋកិច្ចអភិវឌ្ឍន៍ និងពាណិជ្ជកម្មដោយប្រព័ន្ធកុំព្យូទ័រ ត្រូវជ្រើសរើសឯកទេសជាសេដ្ឋកិច្ច។ បេក្ខជនដែលមានសញ្ញាបត្រឯកទេសផ្នែកគណនេយ្យនិងហិរញ្ញវត្ថុ ផ្នែកហិរញ្ញវត្ថុ និងធានាគារ អាចជ្រើសរើសឯកទេសគណនេយ្យ។ បេក្ខជនដែលមានសញ្ញាបត្រផ្នែកបុរាណវិទ្យា ត្រូវជ្រើសរើសឯកទេសជាប្រវត្តិវិទ្យា។ បេក្ខជនដែលមានសញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ត្រូវជ្រើសរើសឯកទេសជា ព័ត៌មានវិទ្យា។

២- ចំពោះអតីតនិស្សិតបរិញ្ញាបត្រ ដែលធ្លាប់បានទទួលការបណ្ដុះបណ្ដាលនៅវិទ្យាស្ថានជាតិអប់រំ ហើយសាមីខ្លួនពុំបានទៅបំពេញការងារតាមការចាត់តាំងរបស់ក្រសួង ឬធ្លាប់បានលុបឈ្មោះចេញពីបញ្ជីគរុនិស្សិត ពុំអនុញ្ញាតឱ្យដាក់ពាក្យសុំចុះឈ្មោះប្រឡងបានឡើយ ទោះបីប្រឡងជាប់ ហើយបន្តចូលរៀនក៏នឹងត្រូវលុបឈ្មោះចេញពីបញ្ជីគរុនិស្សិតវិញដោយស្វ័យប្រវត្តិ ។

៣- បេក្ខជនត្រូវជ្រើសរើសប៉ុស្ត៍មុនការប្រឡងជ្រើសរើសទៅតាមតារាងកំណត់ប៉ុស្ត៍របស់ក្រសួង។

៤- បេក្ខជនជាបុគ្គលិក មិនអនុញ្ញាតឱ្យជ្រើសរើសប៉ុស្ត៍ក្រៅពីរាជធានី-ខេត្ត ដែលខ្លួនកំពុងបម្រើការងារជាដាច់ខាត លើកលែងតែបេក្ខជនជាបុគ្គលិកក្រោមឱវាទទីស្ដីការក្រសួងអប់រំ យុវជន និងកីឡា ត្រូវជ្រើស

ជ្រើសប៉ុស្តិ៍នៅរាជធានីភ្នំពេញ។

៥- បេក្ខជនដែលជាបុគ្គលិកអប់រំ បន្ទាប់ពីប្រឡងជាប់ ត្រូវយកលិខិតផ្ដាច់ការងារពីអង្គភាពខ្លួន ទៅតម្កល់ទុកនៅវិទ្យាស្ថានជាតិអប់រំ ដើម្បីធានាឱ្យមាននិយ័តភាពនៃការសិក្សា ដោយរក្សាប្រាក់បៀវត្ស និងប្រាក់បំណាច់មុខងារនៅដដែល តែមិនត្រូវបានទទួលប្រាក់អាហារូបករណ៍ឡើយ។

៦- ក្រោយពេលប្រឡងជាប់ បេក្ខជនត្រូវចូលរៀនតាមកាលបរិច្ឆេទកំណត់របស់វិទ្យាស្ថានជាតិអប់រំ។ ក្នុងករណីអវត្តមានរយៈពេលមួយសប្ដាហ៍ នៃដើមបវេសនកាល វិទ្យាស្ថានជាតិអប់រំត្រូវលុបឈ្មោះចេញពីបញ្ជីគរុនិស្សិត ហើយត្រូវស្នើសុំជ្រើសបេក្ខជនបម្រុងជំនួស តាមលំដាប់នៃចំណាត់ថ្នាក់ជាបន្តបន្ទាប់ ។

៧- បេក្ខជនដែលក្លែងបន្លំសំណុំលិខិតនៃការប្រឡងត្រូវលុបឈ្មោះចេញពីបញ្ជីគរុនិស្សិត។

៨- បេក្ខជនដែលបន្លំដាក់ពាក្យប្រឡងជ្រើសរើសមុខវិជ្ជាឯកទេស ខុសពីសញ្ញាបត្ររបស់ខ្លួនដែលមាននៅក្នុងសេចក្ដីជូនដំណឹង នៅពេលរកឃើញនឹងត្រូវលុបឈ្មោះចេញពីបញ្ជីគរុនិស្សិត ។

៩- បេក្ខជនដែលបន្លំសញ្ញាបត្រ នឹងត្រូវលុបឈ្មោះជាស្វ័យប្រវត្តិ នៅពេលរកឃើញ ព្រមទាំងទទួលទោសតាមច្បាប់ជាធរមាន ។

១០-ចំពោះបេក្ខជនជាបុគ្គលិកដែលជ្រើសរើសប៉ុស្តិ៍ខុសពីរាជធានី-ខេត្ត ដែលខ្លួនកំពុងបម្រើការ ត្រូវលុបឈ្មោះចេញពីបញ្ជីគរុនិស្សិតជាស្វ័យប្រវត្តិនៅពេលរកឃើញ។

១១- បេក្ខជនជាបុគ្គលិកដែលបន្លំសំណុំលិខិតជានិស្សិតសុទ្ធសាធ ត្រូវលុបឈ្មោះចេញពីបញ្ជីនិងពីក្របខណ្ឌ។

ចំពោះព័ត៌មានលម្អិតបន្ថែមផ្សេងទៀត បេក្ខជនអាចទាក់ទងផ្ទាល់ជាមួយ វិទ្យាស្ថានជាតិអប់រំ ស្ថិតនៅកាច់ជ្រុង ខាងជើងជាប់វិមានឯករាជ្យ តាមបណ្ដោយមហាវិថីព្រះនរោត្តម ។

អាស្រ័យហេតុនេះ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី អនុវត្តការងារនេះឱ្យទទួលបានប្រសិទ្ធភាពខ្ពស់។

សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

**ចម្លងជូន៖**

.ទីស្តីការគណៈរដ្ឋមន្ត្រី
.ក្រសួងផែនការ
.ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
.ក្រសួងមុខងារសាធារណៈ
.គ្រប់សាលារាជធានី-ខេត្ត
" ដើម្បីជូនជ្រាបជាព័ត៌មាន "
.គ្រប់អង្គភាព និងសាលាក្រោមឱវាទក្រសួងអយក
" ដើម្បីជាព័ត៌មាន និងផ្សព្វផ្សាយ "
.វិទ្យាស្ថានជាតិអប់រំ " ដើម្បីអនុវត្ត "
.កាលប្បវត្តិ
.ឯកសារ ៖ វិទ្យាស្ថានជាតិអប់រំ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

# តារាងជ្រើសរើសគរុនិស្សិតកម្រិតឧត្តម

## (បរិញ្ញា+១) ជំនាន់ទី ២១ ឆ្នាំសិក្សា ២០១៥-២០១៦

| ល.រ | មុខវិជ្ជាជំនាញ / រាជធានី/ខេត្ត | អក្សរ.ខ្មែរ | បារាំង | អង់គ្លេស | សីល.ពលរដ្ឋ | ចិត្តវិទ្យា | ប្រវត្តិវិទ្យា | ភូមិវិទ្យា | គីមីវិទ្យា | ជីវវិទ្យា | ផែនដីវិទ្យា | រូបវិទ្យា | គណិត | ព័ត៌មាន | សេដ្ឋកិច្ច | កសិកម្ម | អគ្គិសនី | អេឡិចត្រូនិច | គណនេយ្យ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | ភ្នំពេញ | 0 | 0 | 0 | 0 | 1 | 0 | 0 | 1 | 1 | 2 | 0 | 0 | 6 | 4 | 3 | 0 | 0 | 2 | 20 |
| 2 | ស្ទឹងត្រែង | 0 | 0 | 2 | 1 | 1 | 0 | 0 | 1 | 3 | 1 | 0 | 0 | 1 | 1 | 0 | 0 | 0 | 0 | 11 |
| 3 | ព្រះវិហារ | 1 | 0 | 1 | 1 | 1 | 1 | 0 | 2 | 4 | 3 | 1 | 2 | 3 | 2 | 0 | 0 | 0 | 0 | 22 |
| 4 | កោះកុង | 0 | 0 | 0 | 0 | 0 | 0 | 0 | 1 | 1 | 1 | 0 | 0 | 1 | 0 | 1 | 0 | 0 | 0 | 5 |
| 5 | រតនគិរី | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 1 | 1 | 0 | 0 | 0 | 0 | 3 |
| 6 | មណ្ឌលគិរី | 0 | 0 | 0 | 0 | 0 | 0 | 0 | 1 | 1 | 1 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 4 |
| 7 | កណ្ដាល | 6 | 4 | 10 | 2 | 2 | 5 | 6 | 6 | 6 | 7 | 9 | 15 | 8 | 6 | 1 | 2 | 3 | 0 | 98 |
| 8 | កំពង់ឆ្នាំង | 7 | 2 | 5 | 2 | 1 | 4 | 2 | 3 | 2 | 2 | 2 | 7 | 3 | 2 | 2 | 2 | 3 | 0 | 51 |
| 9 | កំពង់ស្ពឺ | 6 | 2 | 4 | 3 | 1 | 4 | 2 | 4 | 4 | 3 | 4 | 13 | 5 | 3 | 0 | 0 | 0 | 0 | 58 |
| 10 | បាត់ដំបង | 7 | 2 | 5 | 6 | 2 | 4 | 6 | 2 | 7 | 5 | 3 | 14 | 6 | 3 | 1 | 0 | 0 | 0 | 73 |
| 11 | ពោធិ៍សាត់ | 1 | 0 | 1 | 1 | 1 | 1 | 2 | 1 | 2 | 2 | 2 | 3 | 2 | 1 | 0 | 0 | 0 | 0 | 20 |
| 12 | បន្ទាយមានជ័យ | 2 | 0 | 2 | 1 | 1 | 1 | 2 | 1 | 3 | 1 | 1 | 3 | 2 | 0 | 0 | 0 | 0 | 0 | 20 |
| 13 | សៀមរាប | 7 | 3 | 7 | 7 | 2 | 6 | 6 | 7 | 8 | 6 | 5 | 13 | 8 | 5 | 1 | 2 | 2 | 0 | 95 |
| 14 | ឧត្តរមានជ័យ | 1 | 0 | 0 | 0 | 0 | 1 | 1 | 2 | 2 | 1 | 1 | 2 | 1 | 0 | 0 | 0 | 0 | 0 | 12 |
| 15 | ប៉ៃលិន | 0 | 0 | 0 | 1 | 0 | 0 | 2 | 0 | 1 | 1 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 6 |
| 16 | កំពង់ចាម | 14 | 2 | 8 | 7 | 2 | 8 | 6 | 6 | 7 | 9 | 8 | 15 | 8 | 4 | 0 | 0 | 0 | 0 | 104 |
| 17 | កំពង់ធំ | 5 | 0 | 3 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 6 | 2 | 2 | 1 | 2 | 2 | 0 | 31 |

| ល.រ | រាជធានី/ខេត្ត \ មុខវិជ្ជាជំនាញ | អក្សរ.ខ្មែរ | បារាំង | អង់គ្លេស | សីល.ពលរដ្ឋ | ចិត្តវិទ្យា | ប្រវត្តិវិទ្យា | ភូមិវិទ្យា | គីមីវិទ្យា | ជីវវិទ្យា | ផែនដីវិទ្យា | រូបវិទ្យា | គណិត | ព័ត៌មាន | សេដ្ឋកិច្ច | កសិកម្ម | អគ្គីសនី | អេឡិចត្រូនិច | គណនេយ្យ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 18 | ក្រចេះ | 2 | 0 | 2 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 2 | 0 | 0 | 0 | 0 | 0 | 15 |
| 19 | ត្បូងឃ្មុំ | 3 | 1 | 5 | 4 | 0 | 4 | 4 | 3 | 5 | 2 | 2 | 6 | 5 | 1 | 0 | 0 | 0 | 0 | 45 |
| 20 | ព្រៃវែង | 12 | 2 | 7 | 6 | 2 | 7 | 6 | 6 | 6 | 7 | 6 | 15 | 6 | 3 | 0 | 0 | 0 | 0 | 91 |
| 21 | ស្វាយរៀង | 8 | 0 | 2 | 2 | 1 | 3 | 2 | 2 | 3 | 2 | 2 | 9 | 2 | 1 | 0 | 2 | 0 | 3 | 44 |
| 22 | តាកែវ | 12 | 2 | 7 | 6 | 2 | 6 | 6 | 8 | 8 | 7 | 9 | 17 | 10 | 4 | 0 | 0 | 0 | 0 | 104 |
| 23 | កំពត | 5 | 1 | 5 | 4 | 0 | 5 | 5 | 3 | 4 | 5 | 5 | 9 | 5 | 3 | 1 | 0 | 0 | 0 | 60 |
| 24 | ព្រះសីហនុ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 3 | 3 | 0 | 0 | 3 | 1 | 0 | 0 | 0 | 0 | 10 |
| 25 | កែប | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 1 | 1 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 3 |
| | សរុបរួម | 99 | 21 | 77 | 56 | 22 | 62 | 60 | 62 | 84 | 74 | 62 | 150 | 93 | 47 | 11 | 10 | 10 | 5 | 1000 |

**បញ្ជាក់:** បេក្ខជនជាបុគ្គលិកមកពីខេត្តណា ត្រូវជ្រើសរើសប៉ុស្តិ៍នៅខេត្តនោះ ។ ដោយឡែក បេក្ខជនជាបុគ្គលិកមកពីអង្គភាពក្រោមឱវាទទីស្តីការក្រសួង និងរាជធានីភ្នំពេញ ត្រូវជ្រើសរើសប៉ុស្តិ៍នៅរាជធានីភ្នំពេញ ។

រាជធានីភ្នំពេញ ថ្ងៃទី... ខែកក្កដា ឆ្នាំ២០១៥

ប្រធាននាយកដ្ឋានបុគ្គលិក

ឡេង សុផន

បានឃើញ និងឯកភាព

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិត ហង់ ជួន ណារ៉ុន